មន្ទីរកសិកម្មខេត្តរតនគិរី

អាយ, ហ្វាត

# បច្ចេកទេសដាំដំណាំបន្លែ

រៀបចំដោយ: មន្ទីរកសិកម្មខេត្តរតនគិរី

ឧបត្ថម្ភដោយ: មូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម IFAD Grant No-DSF-8005

ឆ្នាំ ២០១០

?.ភ.ឯ.ត AIDOC
...e: 247-048
...ate:
Donated by:

# មាតិកា

**ចំណងជើង** **ទំព័រ**

**ដំណាំស្ពៃខៀវ**......3
I.ស្ថានភាពទូទៅ......3
II.បច្ចេកទេសដាំដុះ......3
១.ការជ្រើសរើសរដូវ......3
២.ការជ្រើសរើសពូជ......4
៣.ការជ្រើសរើស និងការរៀបចំ......5
៤.ការសាបកូន និង ការដាំដុះ......6
៥. ការជ្រំជ្រោយដី......7
៦. ការស្រោចទឹក......7
៧.ការដាក់ជី......8
III.ជំងឺ និង សត្វល្អិត......8
១.អំពីជំងឺ......8
២.អំពីសត្វល្អិតសំខាន់ៗ......9
៣.វិធានការណ៍ការពារ......10
IV.ការប្រមូលផល......10
**ត្រកួនចិន រឺ ត្រកួនគោក**......11
I.សេចក្តីផ្តើម......11
II.បច្ចេកទេសដាំដុះ......11
ការជ្រើសរើសពូជ និង គ្រាប់......11
III.ការប្រមូលផល......12
**ដំណាំត្រប់**......14
I.សារៈប្រយោជន៍......14
II.ពូជ និង ការជ្រើសរើសពូជ......14
III.បច្ចេកទេសអនុវត្តក្នុងថ្នាល......14

IV. ការជ្រើសរើសដី និង រដូវកាលដាំដុះ....................15
V. បច្ចេកទេសដាំ និង ថែទាំ....................15
VI. ការប្រមូលផល....................16
**សណ្តែកកួរ រឺ សណ្តែកទ្រើង**....................17
I.សេចក្តីផ្តើម....................17
II.បច្ចេកទេសដាំសណ្តែកទ្រើង....................17
III. ការថែទាំ....................18
IV. ការប្រមូលផល....................18
V. ការទុកពូជ....................19

# ដំណាំស្ពៃខៀវ

## I. *ស្ថានភាពទូទៅ*

ស្ពៃខៀវ ជាប្រភេទបន្លែមួយក្នុងចំណោមបន្លែស្ពៃជាច្រើនមុខដែលប្រជាកសិករយើងស្គាល់ច្បាស់ និងបរិភោគគេអាចហៅឈ្មោះបានច្រើនយ៉ាង ដូចជាស្ពៃខ្មៅ ស្ពៃហាង ស្ពៃឬស ប៉ុន្តែឈ្មោះដែលគេប្រើទូលំទូលាយគឺ ស្ពៃខៀវ ។នៅតំបន់អាស៊ីគេអាចហៅបាន ៣ យ៉ាងគឺ ស្ពៃស្លឹក ស្ពៃឥណ្ឌា ឬស្ពៃចិន ។ ស្ពៃនេះត្រូវបានគេចាត់បញ្ចូលទៅក្នុងគ្រួសារគ្រុយស៊ីហ្វេរ ។ នៅឆ្នាំ ១៩៣២ លោកម៉ែន តុន បានអោយឈ្មោះជាលើកដំបូងដែលចាត់ចូលទៅក្នុងជំពូក Brassiceae ជាអនុផ្នែកនៃក្រុម Brassica នៅក្នុងក្រុមនេះមានជាង ១០០ ប្រភេទនៃរុក្ខជាតិ ។ស្ពៃនេះមានឈ្មោះវិទ្យាសាស្ត្រថា Brassica Junces-L ហើយវាមានប្រភពនៅតំបន់អាស៊ីកណ្តាលជាពិសេសនៅភាគខាងកើតប្រទេសចិន និង ប្រទេសឥណ្ឌា ។

នៅប្រទេសកម្ពុជា គេដាំស្ទើរគ្រប់ទីកន្លែង និងគ្រប់រដូវ ជាពិសេសនៅរដូវរំហើយ ហើយការបរិភោគដំអាចធ្វើទៅបានតាមចំណង់ចំណូលចិត្តបរិភោគ ។ ដំណាំប្រភេទនេះសម្បូរទៅដោយជីវជាតិដូចតារាងខាងក្រោម :

***តារាងអាហារូបត្ថម្ភក្នុងទំងន់ ១០០ ក្រាមបរិភោគបាន***

| *ទឹក %* | *កាឡូរី* | *កាបូនអ៊ីដ្រាត %* | *ប្រូតេអ៊ីន* | *ខ្លាញ់* | *ការ៉ូតែន* |
|---|---|---|---|---|---|
| | | | *ក្រាម* | *ក្រាម* | *ug* |
| *៨០.៨* | *៣៤* | *៣.២* | *៤* | *០.៦* | *២៦២២* |

| *ស្យាមីន* | *រីបូផ្លាវីន* | *វីតាមីនសេ* | *កាល់ស្យូម* | *ដែក* |
|---|---|---|---|---|
| *ម.ក្រាម* | *ម.ក្រាម* | *ម.ក្រាម* | *ម.ក្រាម* | *ម.ក្រាម* |
| *០.០៣* | *០* | *៣៣* | *១៩៥* | *១៦.៣* |

## II. *បច្ចេកទេសដាំដុះ*

១-ការជ្រើសរើសរដូវ

ដំណាំស្ពៃខៀវ ក៏ជាដំណាំមួយមិនប្រកាន់រដូវដែរ ប៉ុន្តែការជ្រើសរើសរដូវក្នុងគោលបំណងជៀសផុតពីការបំផ្លាញសត្វល្អិតចង្រៃ រដូវដែលសមស្របគឺ ខែតុលា ដល់ខែធ្នូ និង ពីខែកក្កដា ដល់ខែតុលា ចំពោះតំបន់ខ្ពង់រាប និងភ្នំសីតុណ្ហភាពដំប្រ

សើរបំផុតគឺពីចន្លោះ ២០-២៤ °C មធ្យមប្រចាំថ្ងៃ ។ បច្ចេកទេសដាំដុះគឺរាប់បញ្ចូលទៅលើការជ្រើសពូជ ការជ្រើសរើសដី ការរៀបចំដី ការសាបកូន និង ការដាំដុះ ។



២-ការជ្រើសរើសពូជ

ការជ្រើសរើសពូជជាកត្តាយ៉ាងចំបងក្នុងការដាំដុះព្រោះវាជាមុខរបរមួយយ៉ាងសំខាន់ក្នុងការកំណត់ទិន្នផល ។ លក្ខខណ្ឌសំខាន់ៗដែលត្រូវជ្រើសរើសមាន :



- ពូជដែលមានប្រភពច្បាស់លាស់
- សុខភាពរបស់ពូជល្អ ( ប្រមូលផលពេលទុំពេញលេញសិរីតសំរាំង និងទុកដាក់អោយបានត្រឹមត្រូវ គ្មានសត្វល្អិត បំផ្លាញដុះភាគរយខ្ពស់ពី ៨០-៩៥ % ) ។
- ភាពសុទ្ធនៃពូជ ( គ្រាប់ពូជដែលមានភាពស្មើការលូតលាស់មានលក្ខណៈឯកសណ្ឋានទាំងទ្រង់ទ្រាយស្លឹក ធាង និង ពណ៌ ) ។
- អាយុកាលលូតលាស់ខ្លី ទិន្នផលខ្ពស់សមស្របក្នុងការប្រើប្រាស់លើទីផ្សារ ។នៅក្នុងប្រទេសកម្ពុជាយើងបច្ចុប្បន្នពិនិត្យឃើញមានពូជស្ពៃខៀវ ៣ ប្រភេទ :

**ក-** ប្រភេទស្លឹកតូចវែង ( គ្រាប់តូចល្អិតក្រហមហើយមូលវែង ពូជនេះអាយុកាលពី ២៥-៣០ ថ្ងៃចេញផ្កា ស្លឹកស្តើងតែមស្លឹកដូចធ្មេញរណារ ធាងពណ៌បៃតងស្រាល ឫសព្រលែតពូជនេះទិន្នផលទាបជាមធ្យម ១១.៥តោន-១៤តោន/ហ.ត ។

**ខ-** ប្រភេទស្លឹកធំលាតត្រដាងហើយធ្លាក់ចុះក្រោម គ្រាប់ពូជទំហំធំបង្គួរ ហើយមូលពណ៌ក្រហម វាមានអាយុកាលមធ្យមពី ៣០-៤០ថ្ងៃចេញផ្កាស្លឹកពណ៌បៃតងចំមូល ទ្រនុងសរសៃតូចល្អិតធាងពណ៌ទឹកអំពៅខ្ចៅខ្ចី ធំសំប៉ែត

ហើយវែងទិន្ន ផលចន្លោះពី ១៥-១៧ តោន/ហ.ត ប៉ុន្តែមិនធន់ទ្រាំនៅរដូវភ្លៀងព្រោះស្លឹកស្តើង ។

គ- ពូជស្លឹកក្រាសធាងធំពណ៌ស គ្រាប់របស់វាធំៗហើយមានលក្ខណៈជ្រុងៗពណ៌ក្រម៉ៅវាមានអាយុកាលពី ៣៥-៤៥ ថ្ងៃទើបចេញផ្កា ស្លឹកពណ៌បៃតងចាស់ មានរោមខ្លីៗ សសៃស្លឹកពណ៌ស ស្លឹកឈរត្រង់ហើយរួញៗ ធាងនៃស្លឹកពណ៌សស្រអាប់ មានសសៃច្រើនហើយស្វិត វាមានទិន្នផលខ្ពស់ចន្លោះពី ១៨-២២ តោន/ហ.តហើយធន់ទ្រាំនឹងទឹកភ្លៀងអាចដាំបានគ្រប់រដូវ ។

ជាទូទៅដើម្បីសាបលើផ្ទៃដី ១ ហ.ត គេប្រើគ្រាប់ពូជចំនួន ៤៥០០ ក្រាម ប៉ុន្តែចំពោះការសាបហើយដកកូនយកទៅស្ទូងគេប្រើគ្រាប់ពូជចំនួន ២៥០០ ក្រាម ចំនួន ១០០០ គ្រាប់មានទំងន់ ២.៥-៣.២ ក្រាម ។

**៣-ការជ្រើសរើស និង ការរៀបចំដី**



**-ការជ្រើសរើសដី :** ដំណាំប្រភេទនេះត្រូវការដីធូរមានជីជាតិគ្រប់គ្រាន់ ស្រទាប់ដាំដុះជ្រៅស្ងួតទឹកល្អក្រោយពីស្រោច ឬ ភ្លៀង ដូចជាប្រភេទដីគ្រួសខ្មៅ ដីក្រហម ដីល្បាតខ្សាច់ ដីល្បប់ក្បែរមាត់ទន្លេ ឬព្រែក ដីល្បាយធម្មតា ប៉ុន្តែវាមិន អាចទទួលទិន្នផលល្អប្រសើរប្រភេទដីឥដ្ឋ ឬ ដីកណ្តេងខ្លាំងឡើយ ជាមធ្យមតម្រូវការដីដែលមាន Ph ចន្លោះពី ៥.៥-៧.៥ ។



**-ការរៀបចំដី :** ដីសំរាប់ដាំស្ពៃត្រូវរាស់ប្រមូលយកស្មៅ និង កាកសំណល់រុក្ខជាតិ និងដំណាំផ្សេងៗពីរដូវមុនចេញ ហើយភ្ជួរហាលដីអោយស្ងួតរយៈពេល៥-៧ ថ្ងៃ ហើយរាស់បំបែកដីអោយហ្មត់ដើម្បីអោយស្មៅចង្រៃងាប់ និងដីធូរល្អ ។

ការភ្ជួររាស់ត្រូវធ្វើអោយបានច្រើនលើក២-៣ ដងទើបអាចលើករងបាន របៀបលើករង ឬថ្នាលគឺត្រូវអោយមានទទឹងប្រវែង ១ ម៉ែត្រ ចន្លោះរង ២០-៣០ ស.ម បណ្តោយទៅតាមសភាពដីហើយកំពស់រង ១៥-២០ ស.ម បន្ទាប់មករាស់ និង វាយបំបែកដីលើរងឱ្យល្អិតក្បៀរអោយស្មើរតាមរងនិមួយៗ ។

### ៤-ការសាបកូន និង ការដាំដុះ

ការដាំដុះដំណាំស្ពៃក្តោបគេអាចដាំបាន២របៀបគឺ ការសាបកូនហើយដកយកទៅស្ទូង ឬ ការសាបគ្រាប់ឱ្យរង្វើលៗ ហើយដករំលោះកូនចេញដោយទុកឱ្យមានចន្លោះគុម្ព ១៥ស.ម-២០ស.ម ។



ក-វិធីសាស្ត្រសាបកូន

ថ្នាលសម្រាប់សាបកូន ត្រូវកាប់ហាលដីឱ្យស្ងួត វាយបំបែកដីឱ្យល្អិតជ្រោយ និង ហាលដីឱ្យបានច្រើនលើក ក្បៀរឱ្យស្មើ បាចជី ១៥-១៥-១៥ ចំនួន ២០០ ក្រាម ក្នុងផ្ទៃដី ១០ $ម^2$ និងរោយថ្នាំ Furadan ការពារ និង កំចាត់សត្វល្អិតនៅក្នុងដី បន្ទាប់មកយកគ្រាប់ស្ពៃទៅត្រាំទឹក២ ម៉ោង ហើយផ្អាប់១ យប់បន្ទាប់មកយកទៅសាប ។ចំនួន ២ ស្លាបព្រាបាយគ្រាប់ស្ពៃ (២៥ ក្រាម) លើផ្ទៃថ្នាល ១០ $ម^2$ ក្រោយសាបហើយ ត្រូវយកកំទេចចំបើងស្ងួតកាត់ខ្លីៗបាចលើ ហើយស្រោចទឹកឱ្យជោគ ប្រសិនបើនៅរដូវវស្សាគួរធ្វើតំរបការពារភ្លៀង និង កំដៅ ។

ការថែទាំកូនស្ពៃ : ក្រោយពីសាបរយៈពេល ៧ ថ្ងៃ ស្រោចជីបំប៉នឱ្យកូនស្ពៃក្រៅពីនោះការដកស្មៅ និងការកំចាត់សត្វល្អិតក៏ត្រូវធ្វើឡើងដែរប្រសិនបើមានស្មៅ ឬ សត្វល្អិតបំផ្លាញ ។ពេលកូនស្ពៃមានអាយុ ១៥-១៨ ថ្ងៃមានសន្លឹកពី ២-៣ អាចយកទៅស្ទូងបាន ។

ខ-វិធីសាស្ត្រស្ទូងកូនស្ពៃ

ត្រូវស្រោចទឹកថ្នាលកូនស្ពៃឱ្យជោកមុនដកកូនស្ពៃរយៈ ៣០ នាទីក្រោយមកដកកូនស្ពៃថ្នមៗការពារដាច់ឫស និង របួយគល់ និង បាក់ធាងស្ពៃ ។ ការដក់ត្រូវជំរើសកូនស្ពៃដែលធំស្មើគ្នាល្អ ។ ក្រោយដកហើយត្រូវយកទៅស្ទូងលើថ្នាលដែលរៀបចំហើយ តែមុនស្ទូងត្រូវស្រោចទឹកលើថ្នាលឱ្យជោគបាចកំទេចចំបើងដែលកាត់ខ្លីៗរួចជាស្រេចពីលើថ្នាល ទើបស្ទូងកូនស្ពៃ ចន្លោះគុម្ព ១៥ ស.ម និង ចន្លោះជួរ ២០ ស.ម ក្រោយស្ទូងហើយត្រូវស្រោចទឹកឱ្យជោគភ្លាម។

គ-ការដាំដោយសាបគ្រាប់ផ្ទាល់

ការដាំដោយសាបគ្រាប់ផ្ទាល់ គេត្រូវយកគ្រាប់ពូជមួយស្លាបព្រាបាយស្មើសាបរង្វើល១លើផ្ទៃដី ១០ ម$^{២}$ (មួយថ្នាល) ហើយរោយកំទេចចំបើងខ្ចី១ ពីលើបន្ទាប់មកស្រោចទឹកអោយជោគ ព្រឹក ល្ងាច រហូតដល់ពេលស្ពៃមានអាយុ ១០ ថ្ងៃទើបដកវំលោះកូនចេញលើកទី ១ ទុកឱ្យរង្វើល និងលើកទី ២ គឺ ១៥ ថ្ងៃក្រោយសាបត្រូវដកវំលោះដោយទុកឱ្យមានចន្លោះ ១៥ ស.ម និង ចន្លោះជួរ ២០ ស.ម ហើយត្រូវស្រោចទឹក និង ជីបំប៉នឱ្យបានច្រើន ធ្វើឱ្យស្ពៃឆាប់លូតលាស់ ។



**៥-ការជ្រំជ្រោយដី**

ការជ្រំជ្រោយដីក្រោយក្រោយពីស្ទូងបានរយៈពេល ៧-១០ ថ្ងៃ គឺធ្វើឱ្យដីធូរ ជ្រាបទឹកល្អ មានខ្យល់គ្រប់គ្រាន់សំរួលដល់ការលូតលាស់ព្រមទាំងបន្ថយការដុះស្មៅ ។មុនជ្រុំជ្រោយដីឡើងវិញត្រូវដក់ស្មៅចេញផ្អាកការស្រោចទឹក ១-២ ថ្ងៃ ទើបអាចជ្រំបានប្រើដោយចបកាប់បំបែកដីមុខលើ និង ហាលដីនោះ១ ថ្ងៃឱ្យស្ងួត និងឱ្យស្មៅចង្រៃលែងលូតលាស់ ។ គេអាចដកស្មៅលើកទីពីរ នៅពេលស្ពៃមានអាយុ ២៥ ថ្ងៃក្រោយស្ទូងតែហាមជ្រំជ្រោយដី ។

**៦-ការស្រោចទឹក**

ដំណាំប្រភេទនេះមិនត្រូវការទឹកខ្លាំងពេកទេ ប៉ុន្តែវាត្រូវការទឹករាល់ថ្ងៃ ។ជាធម្មតាស្រោចទឹក ២ ដងគឺព្រឹក និង ល្ងាចដោយប៉ោត និង ដោយម៉ាស៊ីនបាញ់ទឹក ។នៅរដូវវស្សាកាលណាមានភ្លៀងធ្លាក់នៅពេលយប់ ឬ ព្រលឹមឡើងគេត្រូវស្រោចទឹក ឬបាញ់ទឹកលាងស្លឹកស្ពៃឱ្យស្អាតកំទេចដីដែលជាប់ ឬដល់នៅក្នុងបណ្តូលស្ពៃដែលជាហេតុធ្វើឱ្យរលួយបាន ។គេចែកការស្រោចស្រពជា ២ ការស្រោចស្រពទឹកជាមធ្យម តែចាប់ពីពេលមានសន្លឹក ៣ ឡើងទៅ ការស្រោចស្រពត្រូវបង្កើនបរិមាណទឹក ឬចាប់ពីពេលស្ទូងហើយរហូតដល់ពេលប្រមូលផល ។



### ៧-ការដាក់ជី

ដំណាំស្ពៃត្រូវការសារធាតុចិញ្ចឹម ៣ សំខាន់ៗ ដូចជាដំណាំឯទៀតដែរ ប៉ុន្តែវាត្រូវការកំរិតខុសគ្នាទៅតាមអាយុកាលរបស់វា។ សារធាតុសំខាន់មានអាសូត ផូស្វ័រ និង ប៉ូតាស្យូម ។ប៉ុន្តែទោះជាយ៉ាងណាក៏ដោយស្ពៃប្រភេទនេះជាដំណាំយកស្លឹកវាត្រូវការ ធាតុអាសូតច្រើនជាងសារធាតុផ្សេងៗទៀត ។គេចែកការដាក់ជី ជា ៣ដំណាក់កាលគឺ :

-ដំណាក់កាលមុនពេលសាបគ្រាប់ ឬ ស្ទូង គេប្រើប្រភេទជី ១៥-១៥-១៥ ចំនួន ១៣៥ គ.ក្រ សម្រាប់ផ្ទៃដី ១ ហ.ត ឬ ១០០-១៥០ ក្រាម (១ ខាំ-១,៥ខាំ) សម្រាប់ផ្ទៃដី ១០ ម$^{២}$ មុនពេលសាបគ្រាប់ស្ពៃ ឬ ស្ទូងកូន ស្ពៃត្រូវបាចលើថ្នាល ដោយលាយជាមួយជីកំប៉ុស្ត ឬកាកសំណល់ពុកផុយដូចជាលាកមកសត្វមាន់ គោ ក្របី ជ្រូក ។ល។ ចំនួន ១០-១៥ គ.ក្រ ហើយរាស់លុបទៅក្នុងដី ។

-ការស្រោចជីបំប៉ន ដោយយកប្រភេទជីអ៊ុយរ៉េចំនួន ៦៥ គ.ក្រ លាយទឹកស្រោចលើផ្ទៃដី ១ ហ.ត របៀបប្រើគឺ ១ស្លាបព្រាបាយ លាយទឹកមួយធុង ស្មើនឹង ១៨ លីត្រ ស្រោចលើផ្ទៃដី ១០ ម$^{២}$ ហើយត្រូវស្រោចទឹកលាងតាមក្រោយអោយជោគការពារកុំអោយជីជាប់ក្នុងកំពូលកូនស្ពៃ ក្រោយពីសាបបាន ៨-១០ ថ្ងៃ ឬក្រោយពីស្ទូង ៥-៧ថ្ងៃ ។

-ការដាក់ជីបំប៉នលើកទី ២ គឺក្រោយសាបរយៈ ១៥-១៨ ថ្ងៃ ឬក្រោយស្ទូង ១០ថ្ងៃ ប្រភេទជី ១៥-១៥-១៥ ចំនួន (១០០-១៥០) លើផ្ទៃដី ១ ថ្នាល ១០ ម$^{២}$ ត្រូវរោយតាមចន្លោះគុម្ពហើយស្រោចទឹកឱ្យជោគ ។

-ការដាក់ជីបំប៉នលើកទី ៣ គឺប្រភេទជីអ៊ុយរ៉េ ៤៦% ស្មើនឹង ៨០-១០០ គ.ក្រលើផ្ទៃដី ១ ហ.ត ឬ២ ស្លាបព្រាបាយលាយជាមួយទឹក ១៨ លីត្រ ស្រោចលើផ្ទៃដី ១០ ម$^{២}$ ក្រោយពីសាបបានអាយុ ២៥-៣០ ថ្ងៃ ឬក្រោយស្ទូង ឬ ២០ថ្ងៃបន្ទាប់មកស្រោចទឹកលាងតាមក្រោយឱ្យជោគ ។

## *III.* អំពីជម្ងឺ សត្វល្អិត

### ១-អំពីជម្ងឺ

**ដំណាំស្ពៃខៀវតែងជួបជម្ងឺសំខាន់ៗ ៣ គឺ :**

**-ដំណាក់កាលសំណាប** : កើតជម្ងឺផ្សិតរលួយគល់ ជម្ងឺនេះបណ្តាលមកពីសំណើមសីតុណ្ហភាព និង សំណើមបរិយាកាសវាបណ្តាលមកពីភ្នាក់ងារបង្ករោគ Rhizocto nia Solani វាតែងតែកើតនៅលើកូនស្ពៃមានអាយុ ៥-១០ថ្ងៃក្រោយពីដាំដុះធ្វើអោយគល់របស់កូនស្ពៃតូចៗរលួយហើយដាច់ក្បែរៗដីវាជាប្រភេទជម្ងឺផ្សិត ។

**-ដំណាក់កាលស្ពៃកំពុងលូតលាស់** : ដំណាក់កាលនេះតែងសង្កេតឃើញស្ពៃរហែកស្លឹកជាភាគៗហើយធ្វើអោយស្លឹកឡើងពណ៌សហើយស្ងួត ករណីនេះវាបណ្តាលមកពីភ្នាក់ងារបង្ករោគ Rhizoctonia Solani វាតែងកើតឡើងក្នុងលក្ខខណ្ឌក្តៅ ហើយសើម ។

**-ដំណាក់កាលលូតលាស់** : គេសង្កេតឃើញស្លឹកស្ពៃរលៀកជាំពេញស្លឹកស្ពៃដូចរលាកទឹកក្ដៅវាកើតលើស្ពៃប្រភេទជាច្រើន ។ ជម្ងឺនេះភាគច្រើនបង្កឡើងដោយលក្ខខណ្ឌដូចជាគ្រាប់ពូជមានជម្ងឺពីរដូវមុន ស្មៅលូតលាស់ច្រើន និង ក្រុមសត្វល្អិតមួយចំនួនជាពិសេសគឺចៃបៃតង និងមមាចជញ្ជក់ស្លឹក ។

**២-សត្វល្អិតសំខាន់ៗ**

សត្វល្អិតសំខាន់ៗលើដំណាំស្ពៃមាន ៣ ប្រភេទគឺ :

**-ដង្កូវយោងទោង** : ការបំផ្លាញមានលក្ខណៈជាក្រុម ការបំផ្លាញខ្លាំងនៅរដូវក្ដៅ ជាពិសេសខែធ្នូ ដល់ខែមេសា ចំណែករដូវវស្សាវាពុំមានលក្ខណៈធ្ងន់ធ្ងរឡើយដោយសារទឹកភ្លៀងមានឥទ្ធិពលធ្វើឱ្យការបង្កកំណើតរបស់វាមានកម្រិតទាប ។

**-ដង្កូវហ្វូង** : ដង្កូវនេះកើតពេញមួយឆ្នាំ ។ ការបំផ្លាញរបស់វាគឺស៊ីជាក្រុមកាត់ស្លឹកខ្ចី ឬចូលទៅជ្រកស៊ីក្នុងបណ្ដូលស្ពៃ វាមានមាឌធំហើយវែងៗ មេអំបៅរបស់វាចូលចិត្តជ្រកក្នុងស្មៅក្រោមស្លឹកជាសំបុកៗ ខ្លះមានស្បែកគំរបការពារពីលើពងវាអាចមានអាយុ ៤០-៤៣ ថ្ងៃហើយដឹកឡើរបស់វាលាក់ខ្លួននៅក្នុងដីលើផ្ទាលដំណាំ ។

**-សត្វទាតូ** : សត្វប្រភេទនេះមិនមែនជាដង្កូវឡើយ គឺវាមានស្លាបអាចលោត ឬហោះហើរបាន មាឌវាតូចៗលក្ខណៈជាហ្វូងៗការបំផ្លាញច្រើននៅរដូវក្ដៅ ជាពិសេសនៅពេលដីស្ងួតមានកំដៅវាអាចកំកើតបានរហ័ស ។

**គេចែកការបំផ្លាញជា ២ បែបគឺ**

កូនទើបនឹងញាស់វាស៊ីឫសស្ពៃនៅក្នុងដីធ្វើឱ្យឫសស្ពៃពុកបន្ថយការលូតលាស់យ៉ាងខ្លាំងព្រោះមេចំណាស់របស់វាពងដាក់ក្នុងដីក្បែរគល់ស្ពៃ ហើយញាស់ស៊ីឫសស្ពៃតែម្ដង។ មេចំណាស់ក្រោយពីពេលវាញាស់មានស្លាបអាចហើរបាន វាអាចហើរទៅទុំលើស្លឹកស្ពៃហើយស៊ីទំលុះស្លឹកស្ពៃ ធ្វើអោយស្ពៃរញ្ជមពេលថ្ងៃ បន្ថយការលូតលាស់យ៉ាងខ្លាំង ហើយស្លឹកស្ពៃមិនអាចលក់បានតម្លៃឡើងគឺក្រិន ។

***វិធានការការពារ***

ការការពារជម្ងឺ និង សត្វល្អិត គេអាចអនុវត្តន៍បានច្រើវិធីសាស្រ្តដូចជា :

**-ការការពារជម្ងឺ** : ការការពារអាចអនុវត្តន៍បានច្រើនវិធីសាស្រ្តដូចជា កំចាត់ស្មៅ ភ្ជួរហាលដីឱ្យស្ងួត ធ្វើគំរបការពារទឹកភ្លៀង ដាំដោយគ្របចំបើង ជ្រើសរើសពូជធន់ ជ្រើសរើសរដូវកាល ។ល។ និងអាចប្រើវិធានការគីមី ដូចជាប្រភេទថ្នាំឈ្មោះ Zined Maneb Mancozeb Captan Cooper hydroxide ដែលអាចយកមកលាយទឹកបាញ់ក្នុងកំរិត ១៥-២០ ក្រាម លាយទឹក១៥-១៨ លីត្រ បាញ់ឱ្យជោគ បន្ថយការស្រោចទឹក និង ស្រោចជីជាពិសេសលើជម្ងឺផ្សិត ។

***ការការពារ និងកំចាត់សត្វល្អិត***

ការការពារ និងកំចាត់សត្វល្អិតអាចអនុវត្តន៍បានច្រើនវិធីដូចជា ការជ្រើរើសរដូវ ជ្រើសរើសពូជ ការរៀបចំដី ។ល។ ចំពោះវិធានការគីមីប្រភេទសត្វល្អិតទាំងនេះមានតែដង្កូវយោងទោងតែប៉ុណ្ណោះដែលពិបាកកំចាត់ព្រោះវាមានកំរិតធន់ទ្រាំទៅ

និងថ្នាំគីមីជាច្រើនប្រភេទ ។ ការកំចាត់សត្វល្អិតឱ្យមានប្រសិទ្ធិភាពខ្ពស់ គឺត្រូវពិនិត្យវត្តមានសត្វល្អិតជាប្រចាំ ហើយត្រូវយល់ដឹងឱ្យច្បាស់អំពីសត្វល្អិតនិមួយជាពិសេស គឺមេអំបៅរបស់វាទៅពេលល្ងាច និងថ្ងៃលិច ប្រសិនបើមានវត្តមានមេអំបៅគឺ ២-៣ ថ្ងៃក្រោយមកលេចចេញវត្តមានការបំផ្លាញជាបន្តបន្ទាប់ ។ការប្រើថ្នាំគីមីដូចជា Diamethoad 60 EC Methylphospate 50 EC, Methyllearbamate 85WP និងថ្នាំប្រភេទ B1 យកមកលាយទឹកក្នុងកំរិត ៣០-៣៥ CC ក្នុងទឹក ១៥-១៨លីត្រ បាញ់ពេលល្ងាច ។

## *IV.* ***ការប្រមូលផល***

ការប្រមូលផល ធ្វើឡើងតាមរបៀបផ្សេងៗគ្នាគេអាចដកទាំងឫស ឬ កាត់យកតែដើមគឺអាស្រ័យទៅតាមតម្រូវការទីផ្សារ ។ ប៉ុន្តែមុននឹងកាត់ឬដកស្ពៃមិនត្រូវស្រោចទឹកឡើយ ទុកអោយស្លឹកស្ពៃស្ងួតការពារភាពជាំ និង កកិត ។ ស្ពៃនេះអាចដក ឬកាត់បានក្រោយពេលសាបរយៈពេល ៣៥-៤៥ ថ្ងៃ ឬក្រោយពីស្ទូង ២៨-៣៥ ថ្ងៃ គឺនៅពេលចេញផ្កាក្រពុំ១ នៅក្នុងបណ្តូល ។ ទិន្នផលមធ្យមចន្លោះពី ១៦-១៨ តោន/ហ.ត វាអាស្រ័យទៅលើការដាំដុះ ថែទាំ និង ប្រភេទពូជ ។

ฯ๛ฯ

# ត្រកួនចិន រឺ ត្រកួនគោក

## I. សេចក្តីផ្តើម



- ត្រកួនជាដំណាំមួយប្រភេទដែលងាយដាំដុះហើយមានរយៈពេលលូតលាស់ល្អ និង សំបូរទៅដោយរូបធាតុចិញ្ចឹម ផ្សេងៗទៀតផង ។

- គេអាចប្រមូលផលត្រកួនបានក្នុងរយៈពេល ២៥ ទៅ ៣០ ថ្ងៃក្រោយពីដាំវា ។

- ក្នុងការដាំដុះប្រជាពលរដ្ឋនិយមកាត់ទុកគល់ត្រឹមដី ដើម្បីអោយវាបែកខ្នែងថ្មី ហើយកាត់លក់ជាបន្តទៀត ។

- បន្លែត្រកួនអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការបានឆាប់រហ័សព្រមទាំងបរិមាណច្រើនទៀតផង ។

- ក្នុងការបរិភោគ គេអាចប្រើត្រកួនជាអន្លក់ ស្រស់ៗ ឬ ចំអិនជាមួយសាច់ ឬ ត្រីក៏បាន

- ពូជត្រកួនដែលប្រជាពលរដ្ឋយើងដាំនៅលើដីគោក សព្វថ្ងៃបានធម្មតាគ្រប់រដូវនោះគឺ ( ត្រកួនគោក ឬ ត្រកួនចិន)

## II. បច្ចេកទេសដាំដុះ

### *ការជ្រើសរើសពូជ និង គ្រាប់*

ពូជ និង គ្រាប់ត្រកួនដែលមានលក្ខណៈដូចតទៅ :

- ដើមដងឈរត្រង់
- គ្រាប់ធំល្មម អត្រាដុះច្រើន
- គ្មានជំងឺ ឬ សត្វល្អិតបំផ្លាញ

### *ការរៀបចំដី*

- ភ្ជួរ ឬ កាប់គល់ហាលដីចោលរយៈពេល ៧-១០ ថ្ងៃ រើសស្មៅចេញឱ្យអស់
- លើករងទទឹង ១ម បណ្តោយតាមលទ្ធភាពដី
- ដាក់ជីលាមកគោ ឬ ជីកំប៉ុស្ត ៣-៤ គីឡូក្រាម ក្នុងដី ១ ម៉ែត្រក្រឡា
- កាប់ច្របល់លាយជីជាមួយដីឱ្យសព្វ ពង្រាបដីឱ្យស្មើ
- ត្រកួនជាដំណាំដែលទាមទារទឹកច្រើន ដូច្នេះ ការធ្វើរង ពិសេសនៅរដូវប្រាំង គួរធ្វើយ៉ាងណាឱ្យទឹកស្ថិតនៅបាន

***របៀបដាំ***

- យកមែកឈើឆូតកូនចង្កូរកាត់ទទឹងរង ប្រវែង ២០ស.ម ឬ ២តឹក ពីជួរមួយទៅជួរមួយ
- រោយគ្រាប់តាមចង្កូរ ដោយដាក់ ២-៣ ស.ម ពីគ្រាប់មួយទៅគ្រាប់មួយ បើសិនជាគ្រាប់ពូជនោះមានអត្រាដុះល្អ
- ដាំក្នុងជំរៅ ០.៥ ស.ម ទៅ ១.៥ ស.ម ។
- នៅពេលដែលមានអាកាសធាតុក្តៅហួតហែង ខ្វះទឹក ឬ ដីជាប្រភេទដីខ្សាច់យើងគួរគ្របរងត្រកួនដោយចំបើង ឬ កំទេចស្មៅស្ងួត ។ ធ្វើរបៀបនេះ គឺធ្វើអោយដីសើមបានយូរ ជួយធ្វើអោយដីធូរបានយូរ ក្រហាប់ និង ទប់ស្កាត់មិនឱ្យស្មៅដុះច្រើនផង ។



***ការថែទាំ***

- ត្រូវឧស្សាហ៍ជ្រោយដីឱ្យបានញឹកញាប់ដើម្បីឱ្យដីធូរ ងាយជ្រាបទឹក ខ្យល់ងាយចេញចូល និង ឬដំណាំដុះលូតលាស់បានល្អដកស្មៅឱ្យស្អាត
- ស្រោចទឹកឱ្យបានជោគ ព្រោះត្រកួនត្រូវការទឹកច្រើន ដើម្បីឱ្យដើមដងលូតលាស់ខ្ចីល្អ មិនក្រិន រឹងចាស់
- ដាក់ជីលាមកគោ ឬ ជីកំប៉ុស្ត ២-៣ គ.ក្រ ឬ អាចម៍ប្រជ្រៀវ អាចម៍មាន់ ១គ.ក្រ ក្នុង ១ ម៉ែត្រក្រឡា ដី ឬ ស្រោចទឹកនោមដែលទុកយូរចំនួន ១កំប៉ុងទឹកដោះគោ លាយជាមួយទឹកចំណុះ ៨-១០ លីត្រហើយស្រោចរយៈពេល ៤-៥ ថ្ងៃម្តង ។
- គួរដាក់ជីកំប៉ុស្ត ឬ ជីលាមកសត្វក្រោយពេលកាត់ភ្លាម១ ឬ មួយអាទិត្យមុនពេលកាត់ ។
- គេអាចកាត់សារជាថ្មីម្តងទៀតក្នុងរយៈពេល ១៨ ទៅ ២០ ថ្ងៃបន្ទាប់មក ។

## III.ការប្រមូលផល

- ការប្រមូលផលអាចធ្វើទៅបានរយៈពេល ២៥-៣០ ថ្ងៃក្រោយពេលដាំ ។ក្នុងពេលនោះត្រកួន អាចផ្តល់ផលបានពេញលេញប្រសិនបើការថែទាំអនុវត្តន៍បានល្អត្រឹមត្រូវ ។
- ការប្រមូលផលដោយដកដើមតាំងពីលើកដំបូង ធ្វើឱ្យចំណាយប្រាក់លើថ្លៃពូជខាតបង់ច្រើន ។ ការកាត់ដើមទុកគល់ ២-៣ ស.ម ពីដីអាចផ្តល់លទ្ធភាពឱ្យគល់ នោះបង្កើតដើមថ្មីដែលមានកំលាំង និង លូតលាស់ធំធាត់ដូចដុះចេញពីគ្រាប់ដែរ ។

- គេអាចប្រមូលផលបាន ៣-៤ សារក្នុងការដាំគ្រាប់ម្តង។ ជៀសវាងការកាត់ត្រួយ ឬ សត្វស៊ីដោយទុកឱ្យដើមនៅវែងចាស់ រឹង និង មិនអាចបង្កើតត្រួយថ្មីដែលមានគុណភាពល្អ ក្នុងរយៈពេលខ្លីបាន ។

## IV. ការប្រមូលគ្រាប់ពូជ

ជាធម្មតាត្រកួនចាប់ផ្តើមចេញផ្កានៅខែតុលា និង ទុំ នៅចុងខែធ្នូ ការចេញផ្កាមានជាបណ្តើរៗ ប៉ុន្តែជាធម្មតាវាផ្តល់ផលល្អត្រឹមខែកុម្ភៈ ទើបកាត់យកទាំងដើមតែម្តង ។ ក្រោយពេលបេះផ្លែ ឬ កាត់ទាំងដើមហើយត្រូវវាយយកទៅហាលឱ្យស្ងួតក្រៀម រួចបុកក្នុងត្បាល់ក្តឿង ហើយអុំយកតែគ្រាប់តែម្តង ។ ពូជដែលគេនាំចូលពីប្រទេសថៃអាចទទួលទិន្នផល ពី ១០០០-១២០០ គ.ក្រ ក្នុងដី ១ ហិកតា ។

ꩫ

# ត្រប់

## I. សារៈប្រយោជន៍

ត្រប់ជាបន្លែមានសារជាតិចិញ្ចឹមច្រើនមុខ ។ យើងអាចបរិភោគត្រប់ជាចំណីស្រស់ក៏បាន អាចចំអិនរួចទើបបរិភោគ។ ផ្លែត្រប់សំបូរណ៍ទៅដោយឋាមពល និង ប្រូតេអ៊ីន ជាពិសេសជីវជាតិ បេ និង សេ ។

## II. ពូជ និង ការជ្រើសរើសពូជ



### *ក- ពូជត្រប់មានៈ*

- ត្រប់វែង ត្រប់ស្រួយ
- ត្រប់ពុតញ្ញង ត្រប់ថ្លុមរមាស

### *ខ- ការជ្រើសរើសពូជ*

- រយៈពេលលូតលាស់ខ្លី
- ធន់ទ្រាំ នឹង ជំងឺ និង សត្វល្អិតបំផ្លាញ
- ផ្តល់ទិន្នផលខ្ពស់

## III. បច្ចេកទេសអនុវត្តក្នុងថ្នាល

### *ក- ការរៀបចំ និង បណ្តុះគ្រាប់*

- លើកថ្នាលសាបជារង ទទឹង ១-១.៥ ម៉ែត្រ
- ធ្វើឱ្យដីបានម៉ត់ល្អ និង ឆូតចង្អូរទទឹងឱ្យបានជំរៅ ១ សង់ទីម៉ែត្រ
- សាបគ្រាប់ចំនួន ៣-៤ ក្រាមក្នុងដី ១ ម៉ែត្រការេ
- រោយដីម៉ត់បំពេញចង្អូរ
- គ្របកូនត្រប់ និងកំទេចចំបើង

### *ខ- ការថែទាំ*



- ស្រោចទឹកឱ្យបានគ្រប់គ្រាន់កុំឱ្យបាក់ពន្លក រហូតដល់កូនត្រប់ដុះពន្លឹក ៣-៤ ។
- ការពារកុំឱ្យសត្វល្អិតស៊ីបំផ្លាញ ដោយរោយផេះ ឬ កំបោរជុំវិញថ្នាល ។

## IV. ការជ្រើសរើសដី និង រដូវកាលដាំដុះ

-គេអាចដាំត្រប់នៅគ្រប់ប្រភេទដី តែល្អបំផុតគឺប្រភេទដីខ្សាច់

-ដំណាំត្រប់ទាមទារសំណើមគ្រប់គ្រាន់ តែឆាប់ចាញ់ទឹក

-ត្រប់អាចលូតលាស់បាននៅធាតុអាកាសក្តៅសើម

-គេអាចដាំត្រប់នៅក្រប់រដូវ

## V. បច្ចេកទេសដាំ និង ថែទាំ



### ក-ការរៀបចំដី

- កាប់ផ្ដាក់ ឬ ភ្ជួររាស់ដីឱ្យបានជ្រៅ
- ហាលដីឱ្យស្ងួតបំបែកដីឱ្យម៉ត់ល្អ
- រើសយកស្មៅចេញឱ្យអស់
- ២០ ថ្ងៃមុនដាំកូនត្រប់ត្រូវបាចកំបោរ

ក្នុងកំរិត ៦-១០ គីឡូក្រាមក្នុងដី ១ អារ

### ខ-ការស្ទូងកូន ឬ ដាំ

- មុនដកកូនត្រប់ទៅដាំ ស្រោចទឹកឱ្យបានជោគល្អ
- ដកកូនឱ្យមានជាប់ដី
- ក្នុងមួយរង ដាំបានតែមួយជួរ
- ដាំចន្លោះ ពីជួរមួយទៅជួរមួយ

១ម៉ែត្រ និង ចន្លោះ ០.៥ ម៉ែត្រ



### គ-ការស្រោចទឹក

-ស្រោចទឹកស្រាល១លើកូនត្រប់បន្ទាប់ពីស្ទូងរហូតដល់ ៣០ថ្ងៃក្រោយពីស្ទូង ។

### ឃ-ការដាក់ជី

- លើកទី ១ ដាក់ជីទ្រាប់បាត : ជីលាមកសត្វចំនួន ៨-១០ តោន ឬ ជី ១៥-១៥-១៥ ចំនួន ៣០០ គីឡូ-ក្រាម ក្នុងដី ១ ហិកតា ។

-លើកទី ២ ជីបំប៉នរយៈពេល ១០-៣០ ថ្ងៃក្រោយពេលស្ទូង : ស្រោចជីអ៊ុយរ៉េចំនួន ៤ ដង ក្នុងកំរិត ១ ស្លាបព្រាបាយ លាយទឹក ២០ លីត្រ ។

-លើកទី ៣ ជីបំប៉ននៅពេលចេញផ្កា : ជី ១៥-១៥-១៥ ចំនួន ១៥០-២០០ គីឡូក្រាម ក្នុងដី ១ ហិកតា។



***ង-ការក្តិចខ្នែង***

ដើម្បីឱ្យគ្រាប់ផ្លែធំ និង មានគុណភាពល្អយើងត្រូវក្តិចខ្នែងមែក ឬត្រួយនៅពេលដែលដើមមេមានមែក ៤-៥ គេក្តិចត្រួយចោលនៅពេលចាប់ផ្តើមផ្កាគេកាត់ស្លឹកនៅឆ្ងាយពីផ្កាចេញ ។

## VI. ការប្រមូលផល

គេអាចប្រមូលផលគ្រាប់នៅពេលដែលផ្លែគ្រាប់នៅខ្ចី ទន់ព្រមទាំងរលោងភ្លឺគ្រាប់មិនទាន់ចេញជារូបរាងពេញលេញ ។

- ការប្រមូលផលគ្រាប់អាចប្រព្រឹត្តិទៅ ២-៣ ថ្ងៃម្តង
- ត្រូវប្រយ័ត្នកុំអោយមានស្នាមឆូត វាអាចធ្វើឱ្យផ្លែគ្រាប់ចុះគុណភាព និង មិនត្រូវកាត់បន្លានៅលើសណ្តង់ចោលទេ
- ទិន្នផលក្នុងសួនបន្លែទទួលបាន ១២០ គីឡូក្រាម ក្នុងដី ១០ ម៉ែត្រការ៉េ ។

៚

# សណ្តែកកួរ រឺ សណ្តែកទ្រើង

## I. សេចក្តីផ្តើម



- សណ្តែកទ្រើងជារុក្ខជាតិបន្លែក្នុងអំបូរសណ្តែកមានអាយុ ត្រឹមតែមួយឆ្នាំងាយដាំ ធំរហ័សហើយដាំបានគ្រប់រដូវ ។
- វាចូលចិត្តធាតុអាកាសក្តៅ តែមិនក្តៅពេកក្នុងសីតុណ្ហភាព ១៦-២៤ អង្សាសេ ហើយជាការល្អបំផុតបើគ្មានភ្លៀង ក្នុងករណីដែលធាតុអាកាសក្តៅបំផុតហើយធ្លាក់ភ្លៀង ច្រើនពេកធ្វើឱ្យផ្កា និង កួរជ្រុះ ។បើធាតុអាកាសត្រជាក់នឹង បង្អាក់ដល់ការលូតលាស់ ។
-គេអាចដាំបាននៅលើដីធូរ ឬ ដីល្បាយខ្សាច់ ។
- សណ្តែកទ្រើងជារុក្ខជាតិបន្លែដែលមានអាយុកាលយកផលរវាង ៥៥-៧៥ ថ្ងៃ រាប់ចាប់ពីដាំគ្រាប់ ។

## II. បច្ចេកទេសដាំសណ្តែកទ្រើង



***ការរៀបចំដី***

- ភ្ជួរ ឬ កាប់គាស់ដីហាលដីចោលរយៈពេល រយៈពេល ៧-១០ ថ្ងៃ
- លើករងទទឹង ១ ម បណ្តោយតាមលទ្ធភាពដី
- ដាក់ជីលាមកគោ ៧-១៥ តោនក្នុងដី ១ ហិកតា
- ចន្លោះជួរ ពី ៥០ សម-៧៥ សម ២ ជួរក្នុង ១ រង

***របៀបដាំ***

- គេនិយមកប់គ្រាប់ក្នុងរណ្តៅពី ៣-៤ គ្រាប់ក្នុងជំរៅ ១.៥ - ២.៥ សម រួចលុបដីឬជីលាមកគោ ឬ ជីធម្មជាតិ។ ស្រោចទឹកឱ្យបានជោគល្អ ទើបយកចំបើង ឬស្មៅស្ងួតគ្របដើម្បីរក្សាសំណើមបានយូរ ។
- រយៈពេលមួយសប្តាហ៍ដើមសណ្តែកដុះចេញសន្លឹកកំណើត ១-២ សន្លឹក
- ត្រូវដកបំបែកកូនចោលទុកតែកូនល្អៗ ១-២ ដើមក្នុង១រណ្តៅ ។ គេប្រើគ្រាប់ពូជ ពី ២០-២៥ គ.ក្រ ក្នុងដី ១ ហិកតា ។

## III. ការថែទាំ

***ការស្រោចទឹក***

- ត្រូវស្រោចទឹកភ្លាមក្រោយពេលដាំរួច និង ស្រោចឱ្យបានទៀងទាត់ដើម្បីរក្សាសំណើមដីសំរាប់ការលូតលាស់ធំធាត់នៃសណ្តែកទ្រើងជាពិសេសនៅពេលចេញផ្កា និង ពេលចាប់ផ្តើមចេញគូរ ។
- ក្នុងករណីខ្វះទឹក ឬ ស្រោចពុំបានដិតដល់បណ្តាលឱ្យជ្រុះផ្កា កូរសណ្តែកក្បៀបស្គម១គ្មានគ្រាប់ ។
- កសិករយើងគប្បីមានទំលាប់ប្រើជីលាមកគោ អាចម៍មាន់ អាចម៍ប្រជៀវ ឬ ជីធម្មជាតិជំនួសជីគីមី ព្រោះជីនោះមានប្រសិទ្ធិភាព និង គុណភាពប្រសើរជាងធ្វើឱ្យដំណាំលូតលាស់ល្អ ផ្លែផ្កាច្រើន ហើយនឹងមានប្រសិទ្ធិភាពក្នុងការកែប្រែគុណភាពដីផង ។ គេអាចងាយស្រួលក្នុងការផលិតដោយខ្លួនឯងតែទាមទារនូវការឧស្សាហ៍ព្យាយាមទៀតផង ។

***ការធ្វើទ្រើង***

- កាលណាសណ្តែកទ្រើងអាយុបាន ១៥-២០ ថ្ងៃ ក្រោយពេលដាំ ឬ ពេលចាប់ផ្តើមចេញសន្លឹកកំណើត ៤-៥ សន្លឹក សណ្តែកទ្រើង នឹងចាប់ផ្តើមលូតចុងដែលចាំបាច់ត្រូវតែមានទ្រើងតោង ។
- ត្រូវយកមែកឈើ ឬ មែកឬស្សីប្រវែង ២ ម៉ែត្រទៅ ២.៥០ ម៉ែត្រ មកដោតនៅមាត់រណ្តៅសំរាប់ឱ្យដើមសណ្តែកទ្រើងរុំពទ្ធ័វាឡើង ។

***ការជ្រោយដី***

- ជ្រោយដីលើកទី ១ : នៅពេលសណ្តែកទ្រើងអាយុ ៧-១០ ថ្ងៃ ក្រោយពេលដាំត្រូវដក ឬ ជំរះស្មៅឱ្យបានស្អាតល្អ ហើយជ្រោយដីឱ្យធូរ
- ជ្រោយដីលើកទី ២ :ធ្វើនៅមុនការដាក់ជីលើកទី២ គឺពេលសណ្តែកទ្រើងមានអាយុ ៣០ ថ្ងៃក្រោយពេលដាំ ។

***ការកាត់មែក***

- ចាំបាច់កាត់មែកចាងចាស់ៗចោលចេញ ដើម្បីឱ្យវាលូតលាស់បានល្អ ។ ក្នុងរដូវភ្លៀងធ្លាក់ជៀសវាងការធ្វើឱ្យរលំដួលនៅដី ព្រោះវាអាចធ្វើឱ្យកូរសណ្តែកទ្រើងខូចខាតដោយមេរោគ សត្វល្អិត ឬ ជំងឺឆ្លងដោយងាយ ។

## IV. ការប្រមូលផល

អាចបេះផលបាននៅពេលសណ្តែកទ្រើងមានអាយុ ៥៥- ៧៥ ថ្ងៃ ។ឧស្សាហ៍បេះឱ្យបានញឹកញាប់ក្នុងរយៈពេល ២-៤ ថ្ងៃម្តង ជៀសវាងកុំឱ្យវាចាស់ទាន់ ។ តាមធម្មតាគេអាចប្រមូលផលសណ្តែកទ្រើងបានប្រហែល ១០-២០ ដងគឺប្រហែល ២០-២៥ ថ្ងៃ ក្នុងមួយអាយុកាលនៃដំណាំនេះ ។

## V. ការទុកពូជ

ចំពោះការទុកពូជ មិនត្រូវឱ្យផ្លែសណ្តែកទុំរហូតដល់កូរស្ងួតជាប់នឹងដើមពេកទេ ។ កាលណាគេសង្កេតឃើញកូរសណ្តែកចាប់ផ្តើមលឿងហើយចាំងគេត្រូវប្រញាប់បេះវាយកមកប្រឡេះគ្រាប់យកទៅហាលទុកធ្វើពូជ ។

## IV វិធីសាស្ត្រធ្វើជីកំប៉ុស្ត

### ១ ការរៀបចំធ្វើកំប៉ុស្តតាមវិធីធម្មតា:

- ការជ្រើសរើសទីកន្លែងសមរម្យ : មិនលិចទឹក . ងាយស្រួលក្នុងការបង្ហូរទឹកចេញយ៉ាងហោចណាស់អាចការពារបានពីទឹកភ្លៀង ។
- ការប្រមូលកាកសំណល់ធម្មជាតិ : លាមកសត្វ កាកសំណលផ្ទះបាយ កាកសំណល់សួនច្បារ ស្រែចំការរួចយកទៅរៀបចំដាក់កន្លែងសំរាប់ធ្វើជីកំប៉ុស្ត ។
- តំរៀបសារធាតុសរីរាង្គទាំងនេះអោយបានកំពស់ ១៥ សង្ទីម៉ែត្រ បន្ទាប់មកត្រូវក្រាលលាមកសត្វយ៉ាងហោចណាស់បានកំពស់ ៥ សង់ទីម៉ែត្រ ។ បន្ទាប់មកទៀតលាយកំបោរ . ផេះអង្កាម ឬដីដែលមានជីជាតិយ៉ាងហោចណាស់អោយបានកំពស់ ៣ សង្ទីម៉ែត្រ ។
  - អនុវត្តន៍ដូចរៀបរាប់ខាងលើរហូតដល់គំនរ ឬរណ្តៅកំប៉ុស្តមានកំពស់ពី ១-១.៥ ម៉ែត្រ ។
  - ស្រោចទឹកពីលើរហូតដល់ជោគល្មម នឹងត្រូវស្រោចជាបន្តបន្ទាប់ដើម្បីអោយគំនរមានសំណើមគ្រប់គ្រាន់ល្អ ។
  - ចូកច្របំអោយបានសព្វល្អដោយប្រើប៉ែល . ចប . បន្ទាប់ពីធ្វើបាន ៣ សប្តាហ៍ ។ បន្ទាប់មកត្រូវចូកច្របល់ម្តងទៀតបន្ទាប់ពីបាន ៥ សប្តាហ៍ ។
  - ជីកំប៉ុសអាចប្រើការបាននៅក្នុងរយៈពេលពី ៣-៤ ខែ ។

### ២ វិធីសាស្ត្រធ្វើជីកំប៉ុស្តរយៈពេល ១៤ ថ្ងៃ :

- កាប់ចិញ្ច្រាំវត្ថុធាតុសរីរាង្គជាកំណាត់តូចៗ (ទាំងស្រើម ស្ងួត និង រុក្ខជាតិបៃតង) ។
- ច្របល់វត្ថុធាតុសរីរាង្គទាំនោះជាមួយលាមកសត្វ . ទឹកម៉ូត . ផេះអង្កាម ក្នុងបរិមាណសមរម្យ ។
- យកវត្ថុដែលលាយទៅដាក់ជាគំនរ ឬរណ្តៅដែលរៀបចំទុកដាក់ជាមុន ។
- ៣-៤ ថ្ងៃក្រោយមកគំនរកំប៉ុស្តគួរតែមានកំដៅ ប្រសិនបើគ្មានកំដៅទេ គួរច្របល់លាមកបន្ថែមទៀត ។
- បន្ទាប់មកត្រូវត្រឡប់គំនររៀងរាល់ ២ ថ្ងៃម្តង ។
- កំប៉ុស្តអាចប្រើបានរយៈពេល ពី១៤-១៥ ថ្ងៃ ។




រូបទី២



## ⌧ វិធីសាស្ត្រធ្វើជីកំប៉ុស្តដែលមាន ៣ ថត :

ថតទាំងបី ត្រូវធ្វើពីឫស្សី ឬក្តារដែលអាចអោយដាក់វត្ថុធាតុសរីរាង្គសំរាប់ធ្វើជីកំប៉ុស្តជាបន្តបន្ទាប់ ។ ថតទីមួយត្រូវដាក់មុនគេ រួចផ្លាស់ប្តូរជាបន្តបន្ទាប់រហូតដល់ថតទី ៣ដែលអាចយកទៅប្រើការបាន ។

- រាយវត្ថុធាតុសំរាប់ធ្វើកំប៉ុស្តនៅថតទី ១
- បន្ថែមដីដែលមានជីជាតិ ឬលាមកសត្វក្នុងបរិមាណសមស្រប
- បន្តធ្វើរបៀបនេះរហូតចេញពីថតទីមួយ
- មួយខែក្រោយមកត្រូវ ត្រឡប់កំប៉ុស្តដាក់ក្នុងថតទី ២ ដោយស្រោចទឹក ឬដាក់វត្ថុធាតុលាមកសត្វបន្ថែមប្រសិនបើចាំបាច់ ។
- គ្របពីលើថតទី ២ដោយដី ឬស្លឹកចេកដើម្បីរក្សាសំណើម ឬកំដៅ ។
- រៀបបំពេញវត្ថុធាតុកំប៉ុស្តក្នុងថតទី ១ បន្តទៀត ។
- មួយខែមកទៀតត្រូវបញ្ចូនសារធាតុកំប៉ុស្តទៅថតទី ៣ ដោយធ្វើយ៉ាងណាអោយមានខ្យល់ចេញចូលបានល្អដោយពុំចាំបាច់ត្រឡប់វត្ថុធាតុទាំងនោះទេ ។
- គ្របពីលើថតទី ៣ ដោយដីពេលនោះសារធាតុកំប៉ុស្តត្រៀមនិងយកទៅប្រើប្រាស់បាន ។
- បំពេញថតទី ២ ម្តងទៀតដោយសារធាតុដែលបានមកពីថតទី ១ រួចគ្របពីលើថតទី២ដោយស្រទាប់ដីស្តើងៗ
- រៀបបំពេញសារធាតុសរីរាង្គក្នុងថតទី ១ ជាបន្តនិងធ្វើរបៀបនេះរហូតទៅតាមសេចក្តីត្រូវការ ។




## ⌧ វិធីសាស្ត្រធ្វើជីកំប៉ុសដោយជីករណ្តៅពាក់កណ្តាល :

- ជ្រើសរើសទីតាំងសមរម្យដែលមិនលិចទឹក
- ជីករណ្តៅទំហំ តាមតំរូវការជំរៅកន្លះម៉ែត្រ

- កាប់ជញ្ជ្រាំវត្ថុធាតុសរីរាង្គជាបំណែកតូចៗរួចច្របល់ជាមួយលាមកសត្វ
- ដាក់ល្បាយនោះក្នុងរណ្តៅរហូតកំពស់ ១ ម៉ែត្រពីមាត់រណ្តៅ
- ប្រើប៉ែល ឬ ដៃធ្វើផ្នែកខាងលើនៃរណ្តៅជារាងការេ
- គ្របពីលើគំនរដោយចំបើង ឬ ស្លឹកចេក ឬជីឥដ្ឋ
- ធ្វើអោយមានខ្យល់ចេញចូលនៅផ្នែកខាងលើនៃគំនរ
- កំប៉ុស្តអាចប្រើបានក្នុងរយៈពេល ១ ទៅ ២ ខែ ។



# ជីកំប៉ុស្តទឹក

## ១.អ្វីទៅជាជីកំប៉ុស្តទឹក?

ជីកំប៉ុស្តទឹក គឺជាជីរាវដែលបានមកតាមរយៈការត្រាំសារធាតុសរីរាង្គ ជាពិសេសលាមកសត្វ មាន់ ទា និង ស្លឹកឈើផ្សេងៗ ។

## ២.ហេតុអ្វីបានចាំបាច់ធ្វើ និងប្រើប្រាស់ជីកំប៉ុស្តទឹកនេះ?

ប្រសិនបើយើងធ្វើអោយបានស្រួលបួល វាសំបូរទៅដោយមីក្រូសរីរាង្គ (សត្វតូចៗដែលមិនអាចមើលនឹងភ្នែកទទេបាន) ដែលមានសារៈប្រយោជន៍ដល់ជីជាតិដី ។ទន្ទឹមនេះជីទឹកក៏មាននូវសារធាតុចិញ្ចឹមដែលរលាយរួចស្រាច់សំរាប់ងាយស្រួលដល់ដំណាំស្រូបយក ។ ប្រសិនបើត្រាំរុក្ខជាតិដែលមានក្លិនខ្លាំង ជីនេះក៏ជួយដេញសត្វល្អិតដែលបំផ្លាញរុក្ខជាតិកុំអោយមកជិតដែរ ។

## ៣.តើវត្ថុធាតុដើមអ្វីខ្លះ ដែលសមស្របសំរាប់ធ្វើជីទឹក ?

សារធាតុសំខាន់ ដែលប្រើសំរាប់ធ្វើជីទឹកមាន :លាមកសត្វមាន់ . ទា .អាចម៍ប្រចៀវ . ស្លឹករុក្ខជាតិដែលមានឫសជ្រៅដូចជា :រុក្ខជាតិដែលដុះដោយឯង ហើយមានក្លិនខ្លាំងដូចជា : ទន្រ្ទានខែត្រ . កន្ទ្រោបព្រៃ ។ល។ ចំពោះស្លឹកពពួកកូរឧទាហរណ៍ : កន្ទំថេត . អង្កាជី . ក៏អាចយកមកធ្វើជាជីកំប៉ុស្តទឹកបានល្អដែល ជាពិសេសប្រសិនបើយើងចង់បានជីជាតិដែលជួយដល់ការលូតលាស់របស់រុក្ខជាតិ ។

## ៤.តើគេធ្វើជីកំប៉ុស្តទឹកយ៉ាងដូចម្តេច ?

### ក. សំភារ:

- គេត្រូវការពាងមួយ
- គេត្រូវការបាវធ្វើពីក្រចៅមួយសំរាប់ច្រក
- ដុំថ្មមួយដុំសំរាប់សង្កត់អោយបាវលិច

### ខ. របៀបធ្វើ

- ច្រកវត្ថុធាតុដើម ស្លឹកឈើ លាមកសត្វ ចូលក្នុងបាវដោយវាស់បរិមាណអោយបានច្បាស់លាស់
- ដាក់បាវដែលច្រកជី ហើយដាក់ចូលក្នុងពាងដាក់ដុំថ្មសង្កត់ពីលើ
- ចាក់ទឹកចូលក្នុងពាងដោយចំណុះទឹកស្មើនឹង ២០ ដងនៃចំណុះជី

ឧ. ប្រសិនបើយើងច្រកជីមួយប៉ោតចូលក្នុងបាវយើងត្រូវចាក់ទឹក ២០ ប៉ោតក្នុងពាង ។

- បិទពាងដោយប្រើគំរបធ្វើពីឈើ

គ. របៀបថែរក្សា

- យើងត្រូវគ្របពាងអោយបានល្អដើម្បីកុំអោយរុយមកពងដាក់ និង ជះក្លិនស្អុយមកក្រៅ
- ដាច់ខាតត្រូវកូរជីជារាងរាល់ថ្ងៃ ដោយមួយថ្ងៃត្រូវកូរពីរដង ។ នៅពេលកូរម្តង១ហើយត្រូវកូរអោយបានប្រហែល ៥ នាទី ហើយរបៀបកូរ គឺកូរបង្វិលទៅ បង្វិលមក ។

ការកូរមានសារៈសំខាន់ណាស់ព្រោះវានាំខ្យល់អុកស៊ីសែនចូលក្នុងពាងហើយបង្កលក្ខណៈអោយសត្វល្អិតដែលរស់នៅត្រូវការអុកស៊ីសែន មានសកម្មភាពខ្លាំង ផ្ទុយទៅវិញបើយើងមិនកូរនោះជីរបស់យើង និងសំបូរមេរោគដែលមិនត្រូវការខ្យល់ ។

**៥.តើការធ្វើជីកំប៉ុស្តយ៉ាងដូចម្តេច ?**

៣ អាទិត្យក្រោយមក យើងអាចដួសទឹកជីយកទៅប្រើបាន ។ យើងអាចដឹងថា ជីរួចរាល់សំរាប់ប្រើបាននៅពេលដែលវាលែងមានក្លិនស្អុយ ។ ជីដែលធ្វើរួចរាល់អាចរក្សាទុកបានប្រហែលរយៈពេល ១ ខែទៀតតែគួរត្រូវទុកវាក្រោមម្លប់នៅពេលដែលរួចរាល់ហើយសំរាប់ប្រើ ។

**សំគាល់ :**

យើងចៀសវាងកុំបោះវត្ថុធាតុដើម ចូលបន្ថែមទៀតគឺប្រើវាអោយអស់សិនរួចចាំធ្វើថ្មីម្តងទៀត ។

៚៙៚